**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**
**អគ្គលេខាធិការដ្ឋាន**

# សេចក្តីប្រកាសព័ត៌មាន

លេខ:.....០៥......./២០១៧អ.កបធ.សជណ

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា នៅថ្ងៃចន្ទ **ទី៣០ ខែមករា ឆ្នាំ២០១៧** វេលាម៉ោង ០៨:៣០នាទី នៅសាលប្រជុំអគារ«ស» វិមានរដ្ឋចំការមន ក្រុមប្រឹក្សាធម្មនុញ្ញបើកសវនាការជំនុំជម្រះជាសាធារណៈលើ ៖

១- សំណុំរឿងលេខ២៦៣/០០១/២០១៧ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ ស្តីពីបណ្តឹងរបស់លោក **ផែង ហេង** មេធាវីតំណាងឲ្យឈ្មោះ **សឿន ជី** ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០០៦ គ.ជ.ប ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧របស់ គ.ជ.ប ដែលមិនបានលុបឈ្មោះជនជាតិបរទេស (វៀតណាម)ចំនួន ៤១នាក់ នៅការិយាល័យលេខ០០១ សង្កាត់លេខ១ ខេត្តព្រះសីហនុ ចេញពីបញ្ជីបោះឆ្នោតដំបូងឆ្នាំ២០១៦ ។

២- សំណុំរឿងលេខ២៦៤/០០២/២០១៧ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ ស្តីពីបណ្តឹងរបស់លោក **ផែង ហេង** មេធាវីតំណាងឲ្យឈ្មោះ **កុំ អ៊ួន** ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០០៧ គ.ជ.ប ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ របស់ គ.ជ.ប ដែលមិនលុបឈ្មោះជនជាតិបរទេស(វៀតណាម) ចំនួន ៣៥ នាក់នៅការិយាល័យលេខ០០២ សង្កាត់លេខ២ ខេត្តព្រះសីហនុ ចេញពីបញ្ជីបោះឆ្នោតដំបូងឆ្នាំ២០១៦ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើសូមសាធារណជនជ្រាប។

រាជធានីភ្នំពេញថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ: (៨៥៥) ២៣ ៧២៦ ០៣១, E-mail: sgccc@online.com.kh / info@ccc.gov.kh, Website :http://www.ccc.gov.kh ,ប្រអប់សំបុត្រ ២៤៨៣ ភ្នំពេញ